# សិទ្ធិស្ត្រីក្នុងវិស័យអប់រំ

( ចង្វាក់ រាំក្បាច់ )  កែសម្រួលដោយក្រសួងវប្បធម៌ ( ៣)

១- មាត្រាទី១០ ក្នុងច្បាប់ក្រុម    ចំណោះជាធំខាងអប់រំ
កុំបីរើសអើងនឹងមាសមុំ[២]    នៅក្នុងសង្គមស្ត្រីក៏មានសិទ្ធិ ។

២- ទីមួយលក្ខខណ្ឌមុខរបរ    ណែនាំសាទរអាជីពពិត
សិទ្ធិបានសិក្សាសញ្ញាប័ត្រ    នៅទីជនបទនិងទីក្រុង ។

៣- សិទ្ធិនេះផ្តល់បានពីបឋម    បច្ចេកមធ្យមគ្រប់ទាំងស្រុង
កុំឱ្យស្ត្រីផុងអន្លុង[៣]    លិ្ងតល្ងង់ទោរទន់គ្មានចំណេះ ។

៤- សិទ្ធិមួយមានន័យជាខ្លឹមសារ    គុណភាពស្មើគ្នាលើលោកនេះ
អប់រំប្រឡងសិទ្ធិចំណេះ[៤]    សំភារៈប្រុសស្មើស្រី ។

៥- សិទ្ធិSclolarshipរៀនបន្ត    អាហារូបករណ៍និងអ្វីៗ
ប្រាក់ថ្លៃសិក្សាជាអចិន្ត្រៃយ៍    ជួយឱ្យស្ត្រីបានចំណេញ[៥] ។

៦- សិក្សារៀនសូត្រអក្ខរកម្ម    កើតជាប្រចាំជួយបំពេញ
ឱ្យស្ត្រីទាំងឡាយផុតទោរម្នេញ    មានសិទ្ធិពេញលេញក្នុងការងារ ។

៧- សិទ្ធិមួយបន្ថយការលះបង់    ក្នុងវ័យជំទង់ភ្លេចសាលា
ព្រោះតែជីវភាពខានសិក្សា    ខ្វះទុនវិជ្ជាមួយជីវិត ។

៨- ឱកាសដូចគ្នាក្នុងកីឡា    មានកាយសិក្សាសុខភាពពិត
ឱវាទដ៏ល្អផែនការគិត    ធ្វើឱ្យសុក្រឹត មានមង្គល ។

៩- សិទ្ធិខាងអប់រំផ្តុំថ្នើងថ្កាន    មាគ៌ាជាស្ពានដែលជួយផ្តល់
ជួយលើកំកើង ជាជន្ទុល    លើកដាក់តំកល់ឱ្យឧត្តម ។

១០- សិទ្ធិនេះបំបាត់ការរើសអើង    នៅក្នុងសង្គមយើងឱ្យភិរម្យ
ជួយស្ត្រីខ្មែរកុំឱ្យល្ងង់    ជាតិយើងគង់វង្សតរៀងទៅ ។